# សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិលស្តីពី ការបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ) នៅក្នុងប្រទេសកម្ពុជា ឆ្លើយតបនឹងអនុសាសន៍នៃការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (UPR) ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក

ភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១៖ នៅក្នុងដំណាក់កាលនៃការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ នូវស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ជុំទី៣ ហៅកាត់ថា (UPR) យើងខ្ញុំជាអង្គការសង្គមស៊ីវិល និងសហគមន៍ដែលធ្វើការលើការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ សិទ្ធិស្ត្រី និងសិទ្ធិកុមារ ដូចមានរាយនាមខាងក្រោម សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានទទួលយកអនុសាសន៍ និងប្រទេសដែលបានផ្តល់អនុសាសន៍ UPR អំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (SOGIESC) ក៏ដូចជាអ្នកពាក់ព័ន្ធ បង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត តាមរយៈការរៀបចំឱ្យមាននូវសកម្មភាពជាក់លាក់ ដើម្បីអនុវត្តអនុសាសន៍នៃសិទ្ធិទាំងនោះប្រកបដោយប្រសិទ្ធភាព។

នៅក្នុងការត្រួតពិនិត្យ UPR ជុំទី៣ ឆ្នាំ២០១៩ ប្រទេសកម្ពុជាបានទទួលយក អនុសាសន៍ចំនួន ៩ អំពីការការពារសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អ្នកអន្តរភេទ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទ (LGBTIQ) ។ អនុសាសន៍ទាំងនោះផ្តោតលើកំណែទម្រង់ច្បាប់ និងគោលនយោបាយ ៣ ជាចម្បងគឺ៖ (១) វិសោធនកម្ម មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុញ្ញាតសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់សម្រាប់ដៃគូភេទដូចគ្នា (២) បង្កើតច្បាប់និងគោលនយោបាយប្រឆាំងការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និង (៣) បង្កើតច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកប្តូរយេនឌ័រ។

ចាប់ពីឆ្នាំ២០១៩មក ពួកយើងបានកត់សម្គាល់ឃើញនូវវឌ្ឍនភាពមួយចំនួនលើការងារលើកកម្ពស់និងការការពារសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា រួមមានការលើកកម្ពស់ការយល់ដឹង និងការទទួលយកអ្នកស្រឡាញ់ភេទដូចគ្នាពីសាធារណជន ដោយមានការចូលរួមចំណែក និងកិច្ចខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ តួយ៉ាងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអង្គការសង្គមស៊ីវិលបានដាក់ចេញនូវកម្មវិធីសិក្សាអំពីការអប់រំរឿងផ្លូវភេទគ្រប់ជ្រុងជ្រោយក្នុងសាលារៀន ដែលបានបញ្ចូលនូវសមភាពយេនឌ័រ និងគោលគំនិតនៃនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ស្របទៅតាមកម្រិតសិក្សានិងភាសាសម្រាប់សិស្ស។ ចំណែកឯក្រសួងកិច្ចការនារីបានដាក់បញ្ចូលស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រ ជាក្រុមងាយរងគ្រោះអាទិភាពមួយ នៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣។ រីឯថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក៏បានថ្លែងការណ៍លើកទឹកចិត្តដល់មន្ត្រីរដ្ឋាភិបាលនៅគ្រប់ជាន់ថ្នាក់ និងសាធារណជនកុំឱ្យមានការរើសអើងប្រឆាំងអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ ទន្ទឹមនឹងនោះ សង្គមស៊ីវិលនៅប្រទេសកម្ពុជា និងសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក៏បានបន្តកិច្ចការងារអប់រំផ្សព្វផ្សាយបង្កើនការយល់ដឹង និងលើកទឹកចិត្តឱ្យមានការទទួលស្គាល់អ្នកស្រឡាញ់ភេទដូចគ្នា ពីក្រុមគ្រួសារ និងសាធារណជនទូទៅទៀតផង។ សកម្មភាពទាំងនេះគឺជាជំហានដំបូងដ៏មានសារៈសំខាន់ដែលទទួលបាននូវការសាទរពីមជ្ឈដ្ឋាននានា ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវការប្តេជ្ញាចិត្តនៅក្នុងការអនុវត្តអនុសាសន៍ UPR។

ថ្វីត្បិតតែមានកិច្ចខិតខំប្រឹងប្រែងដូចរៀបរាប់ខាងលើក្តី ក៏អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជានៅតែបន្តប្រឈមមុខនឹងការរើសអើងក្នុងទម្រង់ផ្សេងៗ ទាំងផ្នែកសង្គមនិងផ្នែកច្បាប់។ មូលហេតុចម្បងៗនៃការរើសអើងគឺដោយសារតែ មិនមានការអនុញ្ញាតឱ្យអ្នកស្រឡាញ់ភេទដូចគ្នាអាចរៀបការស្របច្បាប់ កង្វះការការពារផ្លូវច្បាប់ជាក់លាក់ប្រឆាំងនឹងការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទនៅវិស័យការងារ សុខាភិបាល និងអប់រំ ក៏ដូចជាកង្វះការតាក់តែងច្បាប់ស្តីពីការទទួលស្គាល់អត្តសញ្ញាណយេនឌ័ររបស់បុគ្គលផងដែរ។

យើងសង្កេតឃើញថា ចាប់តាំងពីឆ្នាំ២០១៩មក ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាមិនទាន់រៀបចំឱ្យមានសកម្មភាពជាក់លាក់ក្នុងការឆ្លើយតបនឹងដំណើរការរៀបចំកែប្រែ និងតាក់តែងច្បាប់ ដែលបានកំណត់ក្នុងអនុសាសន៍ UPR អំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ដែលកម្ពុជាទទួលយកនៅជុំទី៣នៅឡើយទេ។ ហេតុដូច្នេះ ដើម្បីបង្កើននូវប្រសិទ្ធភាព និងប្រសិទ្ធផល ឈានទៅដល់ការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាពេញលេញ រួចផុតពីការរើសអើងនៅទូទាំងប្រទេសកម្ពុជា នៅខណៈពេលពាក់កណ្តាលអាណត្តិ និងមុនជុំបន្ទាប់ នៃUPR យើងខ្ញុំទាំងអស់គ្នាសូមស្នើ៖

- រាជរដ្ឋាភិបាលកម្ពុជា ប្រទេសដែលបានផ្តល់អនុសាសន៍ និងស្ថាប័នពាក់ព័ន្ធ បន្តកិច្ចសហការរួមគ្នារៀបចំនូវផែនការសកម្មភាពជាក់លាក់ ក្នុងការអនុវត្តអនុសាសន៍ទាំងនេះ ទាំងផ្នែកគោលនយោបាយនិងច្បាប់ ជាពិសេសការអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។
- រាជរដ្ឋាភិបាលកម្ពុជាពិចារណាបង្កើតក្រុមការងារ ដែលមានសមាសភាពចម្រុះ ដើម្បីទទួលបន្ទុកដឹកនាំ សិក្សាពិនិត្យ និងពិគ្រោះយោបល់លើសេចក្តីព្រាង និងស្នើវិសោធនកម្មច្បាប់ពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុញ្ញាតឱ្យមានអាពាហ៍ពិពាហ៍ស្របច្បាប់សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។ ក្រុមការងារនេះគួរស្ថិតក្រោមការដឹកនាំសម្របសម្រួលរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដោយមូលហេតុថា គ.ស.ម.ក គឺជាស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាដែលមានធនធានបច្ចេកទេសដឹកនាំ និងសម្របសម្រួលយន្តការ UPR ស្រាប់។ សមាជិកក្រុមការងារ ដែលសមាសភាពចម្រុះនេះ គួររាប់បញ្ចូលអ្នកពាក់ព័ន្ធដូចជា ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងស្ថានទូត ជាពិសេសប្រទេសដែលបានផ្តល់អនុសាសន៍ UPR និងអង្គការសង្គមស៊ីវិលធ្វើការលើសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ សិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ សិទ្ធិស្ត្រី សមភាពយេនឌ័រ និងសិទ្ធិកុមារ។

ដរាបណាដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាមិនអាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ នោះអ្នកស្រឡាញ់ភេទដូចគ្នា កូនៗ និងសមាជិកគ្រួសាររបស់ពួកគេនៅតែមានភាពរងគ្រោះបន្តទៀត។ ការអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះ ការមាក់ងាយ និងការរើសអើងប្រឆាំងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងជួយលើកកម្ពស់ឱ្យមានបរិយាបន្ន សុខដុមរមនា និងសុខុមាលភាពសង្គម ដែលឆ្លុះបញ្ចាំងទៅនឹងគុណតម្លៃរបស់ខ្មែរ ទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយនិងរួមចំណែកសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព៕

**សេចក្តីថ្លែងការណ៍រួមនេះមានការចូលរួមគាំទ្រដោយ៖**

១. អង្គការសហាគមន៍ឥន្ទធនូកម្ពុជា
២. ក្រុមយុវជនស្ម័គ្រចិត្តក្តីស្រឡាញ់គឺចម្រុះ
៣. មូលនិធិមីក្រូឥន្ទធនូអន្តរជាតិកម្ពុជា
៤. អង្គការថែទាំសុខភាពគ្រួសារកម្ពុជា
៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
៦. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
៧. អង្គការក្លាហាន
៨. អង្គការសីលការ
៩. អង្គការ *Save the Children (SCI)*
១០. សមាគមចាសអាស៊ីអាគ្នេយ៍
*Just Associate South-East Asia (JASS SEA)*

១១. សមាគមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអ្នកអន្តរភេទអាស៊ី
*International Lesbian, Gay, Bisexual, Trans and Intersex Association Asia (ILGA Asia)*

១២. សមាគមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអ្នកអន្តរភេទពិភពលោក
*International Lesbian, Gay, Bisexual, Trans and Intersex Association World (ILGA World)*

១៣. អង្គការសម្ព័ន្ធអាស៊ីប៉ាស៊ីហ្វិកដើម្បីសុខភាពផ្លូវភេទ និងបន្តពូជ និងសិទ្ធិ
*Asia-Pacific Alliance for Sexual and Reproductive Health and Rights (APA)*

១៤. អង្គការមជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវដើម្បីស្ត្រី
*Asia-Pacific Resource and Research Center for Women (ARROW)*

១៥. មូលនិធិសម្ព័ន្ធអាស៊ីប៉ាស៊ីហ្វិកដើម្បីសុខភាពផ្លូវភេទបុរស
*Asia Pacific Coalition for Male Sexual Health Foundation (APCOM Foundation)*

១៦. ភ្នាក់ងារដើម្បីអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ
*International Women's Development Agency (IWDA)*

**<u>សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖</u>**

១.អង្គការសហាគមន៍ឥន្ទធនូកម្ពុជា ៖ កញ្ញា លី ពិសី 012 697 641
២. ក្រុមយុវជនស្ម័គ្រចិត្តក្តីស្រឡាញ់គឺចម្រុះ ៖ លោក គុយ ធីតា 077 717 475
៣. មូលនិធិមីក្រូឥន្ទធនូអន្តរជាតិកម្ពុជា ៖ កញ្ញា ឈឿង រចនា 093336896
៤. អង្គការថែទាំសុខភាពគ្រួសារកម្ពុជា ៖ លោកស្រីបណ្ឌិត សាផន សុមោលីរស្មី 069 777 855
៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ៖ លោក លឹម បូរិន 012 904 266